# រឿង ស៊ឹមអ្នកបរឡាន

## និពន្ធដោយ លោក អ៊ឹម ថុក

ព.ស ២៤៨៦ គ.ស ១៩៥៦

# ១- ទាលសង់ផ្ទះ

ព្រឹកម៉ោង៩ នៅលើផ្លូវជាតិលេខ១ ចំពីមុខផ្សារត្រីក្រុងភ្នំពេញ រទេះឡានតូច-ធំបើកវឺចុះឡើង ប្រជ្រៀតនឹងស៊ីក្លូ រទេះកង់ រទេះសេះ និងរទេះគោ។នៅក្បែរថ្នល់ខាងកើតឆៀងខាងជើងផ្សារ មានទីលានមួយមានបណ្ដោយប្រហែល៧០ម ទទឹង៣០ម។ក្នុងទីវាលនោះអ្នកធ្វើការប្រុសស្រី បានប្រញាប់កាប់គាស់រែកសែង ញាប់ដៃញាប់ជើង។ខ្លះជីកចង្អូរ ខ្លះបំបែកដុំឥដ្ឋ ដុំបេតុង ខ្លះដងទឹកពីទន្លេសាបយកមកលាងក្រួសអាចម៍ផ្កាយលាយបាយអ។ល។ ហើយបើយើងសង្កេតមើលយូរបន្តិច យើងមុខជានឹងឃើញអ្នកធ្វើការទាំងនោះ មានមុខការខុសគ្នា ធ្វើដោយក្រុមៗនៅក្រោមមេតម្រួតបួននាក់។

ក្នុងក្រុមលាយបេតុង ស្រីប្រុសវៀតណាមធ្វើការលាយចម្រុះគ្នា។អ្នកទាំងអស់គ្នាបែកញើសសស្រាក់ខំធ្វើការតែរៀងខ្លួន ខ្លះជញ្ជូនថ្មដាក់ធុងវាល់ ខ្លះចូកខ្សាច់ ខ្លះលាយបេតុង ខ្លះរែកទឹក ខ្លះលីបាវស៊ីម៉ង់ត៍ ខ្លះទៀតជញ្ជូនបេតុងយកទៅចាក់ឫសផ្ទះ។

ក្នុងក្រុមរៀបជញ្ជាំង ជាងកំបោរ ខ្មែរវៀតណាម បានខំរៀបឥដ្ឋដាក់តជាន់លើគ្នាផ្សារភ្ជាប់នឹងបាយអ។បានមួយជាន់ពីរជាន់ឥដ្ឋ គេផ្ទៀងតម្រង់ខ្សែបន្ទាត់ឲ្យត្រង់ ប្រយ័ត្នកុំឲ្យវៀច។គេខំសម្ងិតសម្អាងណាស់។នៅចម្រុះនឹងពួកជាងកំបោរ មានជាងឈើយកមេទ្វារបង្អួច មកលើកតម្លើង វាយចាងណាងខ្វែងចុះឡើង ប្រើកូនតឹងស្ទង់មេបញ្ឈរ ប្រើកែវស្ទង់មើលមេផ្ដេកឲ្យស្មើ។

ក្នុងក្រុមជីកបន្លាយឫស គូលីស្រីប្រុស ខ្មែរវៀតណាម ចម្រុះគ្នាបាន់ជីកកាប់ដីបំបែកដុំបេតុង គាស់កម្រាលឥដ្ឋ។ខ្លះទៀតកើបដីជញ្ជូនចាក់ឆ្ងាយពីកន្លែងធ្វើការ។

ក្រុមគូលីនោះរាប់អានគ្នាណាស់។គេមិនប្រកាន់ថា អ្នកនេះជាតិនេះ អ្នកនោះជាតិនោះឡើយ។គេនិយាយរកគ្នាដោយស្មោះស្ម័គ្រ គេចំអែចំអន់គ្នាលេង។ក្មេងៗហៅចាស់ៗ ពូមីង យាយតា។ឯចាស់ៗវិញ ហៅក្មេងៗ ក្មួយ ឬចៅ ឬអាមីងទៅតាមការរាប់អានរបស់គេ។ក្រុមគូលីមានចិត្តស្រដៀងគ្នា គំនិតដូចគ្នា ជីវភាពដូចគ្នា ការងារដូចគ្នា ចិត្តដូចគ្នា។សេចក្ដីត្អូញត្អែររបស់កម្មករម្នាក់ ក៏ដូចជាសេចក្ដីត្អូញត្អែររបស់ក្រុមទាំងមូលដែរ។បើម្នាក់បានទទួលផលអាក្រក់ណាមួយ អ្នកឯទៀតបើមិនយូរក៏ឆាប់ ត្រូវទទួលផលអាក្រក់នោះមិនខានដែរ។

នៅក្នុងក្រុមបេតុង មីងប្រេមមានរាងស្គមស្លាំង បានងាកមើលឆ្វេងស្ដាំ មិនឃើញអ្នកតម្រួត ក៏និយាយតិចៗថា៖

- ខ្ញុំខានមួយថ្ងៃអាទិត្យនេះ។
- ហេតុអ្វីក៏ដូចនេះ? (សម្លេងមួយសួរឡើង!)
- អ្នកមិនដឹងឬ? ដើម្បីបានការធ្វើ ខ្ញុំត្រូវបង់ខាតមួយថ្ងៃឲ្យទៅគេណា។

នាយម៉េងដែលជាអ្នកចូកខ្សាច់ ក្រោយដែលបានយកខ្នងដៃជូតញើសថ្ងាស ឆ្លើយតប៖

- មិនមែនតែមីងឯងទេខាតនោះ ខ្ញុំក៏ត្រូវគេកាត់ប្រាក់ឈ្នួលអស់ពីរថ្ងៃដែរ។គេចេះប្រកាន់ថា ខ្ញុំដើរឡានធ្វើឲ្យបែកក្បឿងច្រើន...

- ប្រាក់ឈ្នួលមួយថ្ងៃ១៨រៀល ហើយកាត់មួយថ្ងៃទៅទៀត បានអ្វីស៊ី(មីងប្រេមថ្ងូរ)។យើងជាពួករងកម្ម មែន...
- ពិតមែនហើយ(ម៉េងឆ្លើយ)។យើងបានជាឫសសង្គមខ្មែរ។យើងត្រូវទទួលការធ្ងន់ទាំងប៉ុន្មាន មិនខុស ពីបេតុងឫសផ្ទះយើងធ្វើនេះទេដែលត្រូវទ្រទម្ងន់ផ្ទះសព្វសារពើ ...។

កំពុងតែជជែកថ្លែងទុក្ខប្រាប់គ្នាដូចនេះ ស្រាប់តែសម្លេងមួយខ្លាំងលាន់ថា៖

- ខំធ្វើការឲ្យមែនទែន ខ្ជិលណាស់គិតតែជជែក... ប្រយ័ត្នមិនបើកលុយឲ្យថ្ងៃសៅរ៍អាទិត្យនេះ។
- ចីសែបឲ្យមកហើយរើយកនយើង។ចីនេះជាភ្នែកច្រមុះរបស់ហាង។គាត់បានប្រាក់ខែច្រើនណាស់ ហាង ឲ្យឡានគាត់មួយដើរត្រួតការ (នាងម៉េងបានខ្សឹបប្រាប់កូនគាត់)។

កន្លះម៉ោងក្រោយ ចីសែបឲ្យបានបើកឡានទៅវិញ ម៉េងនិយាយតៈ

- ប្រាំឆ្នាំហើយ ខ្ញុំធ្វើការជាមួយហាងនេះ។ខ្ញុំដើរឡានដឹកឥដ្ឋ ក្បឿង ឈើនៅកំពង់ឆ្នាំង កំពង់ចាម តាកែវ។ហាងបានចំណេញច្រើនណាស់ក្នុងប៉ុន្មានឆ្នាំនេះ ពីដើមមានឡានតែមួយទេ ឥឡូវមានប្រាំបី។ថៅកែ ពីដើមជិះតែស៊ីក្លូ ឥឡូវមានឡានតូចល្អណាស់ ឯចំណែកគូលីវិញ ដូចខ្ញុំជាដើម នៅតែខ្វះច្រករាល់ ពេល។ក្នុងពពួកជើងឈ្នួលហាង មានតែចីសែបឲ្យទេដែលបានគ្រាន់បើមានផ្ទះនៅ មានកូនឡានជិះ។ ហាងនេះទទួលម៉ៅការសង់ផ្ទះ សង់បន្ទាយច្រើនក្នុងប៉ុន្មានឆ្នាំនេះ។

# ២. ថ្ងៃសម្រាក

ព្រះអាទិត្យពេលជិតថ្ងៃត្រង់ ចោលចំហាយក្ដៅដូចគេដុត អ្នកធ្វើការគ្រប់គ្នាអស់កម្លាំងធ្វើការរវើយដៃរវើយជើង ស្នូររគាំងលាន់ឮម៉ឹងៗ។ពេលសម្រាក់ថ្ងៃត្រង់បានពង្រីកមុខអ្នកធ្វើការ។ក្រុមគូលិសើចដាក់គ្នា យកប្រដាប់ប្រដារបស់ខ្លួន មានបង្គី ចបកាប់ ប៉ែល ធុងទឹក។ល។ ទៅប្រគល់ឲ្យអ្នកយាមឃ្លាំង រួចក៏បោសដីពីខ្លួនយ៉ាងប្រញាប់ប្រញាល់ ដើរសំដៅទៅទីកន្លែងរៀងខ្លួន។

គូលិនៅផ្ទះជិត ជាងណាមានកត់ជិះបានត្រឡប់ទៅសម្រាកថ្ងៃត្រង់នៅផ្ទះអាត្មាជួបជុំប្រពន្ធកូន។ឯចំណែកអ្នកគ្មានផ្ទះ ឬមានផ្ទះនៅឆ្ងាយមិនបានត្រឡប់ទៅទីលំនៅក្នុងពេលសម្រាកនេះទេ។ពួកថីកាប៉ូរ៉ាល់បានវិលត្រឡប់ទៅផ្ទះតែសព្វៗខ្លួន។

ក្នុងពពួកគូលិជាប់១០០នាក់ គេឃើញគូលិ២០នាក់បានទៅសម្រាកក្នុងវាលធ្វើការហើយមានខ្លះពិតមែនតែមិនបានត្រឡប់ទៅផ្ទះ បានថយទៅសម្រាកនៅសំយាបផ្ទះ ឬក្រោមម្លប់ឈើលើចិញ្ចើមថ្នល់ក្រៅរបងធ្វើការទៅវិញ។គូលិដែលបានសម្រាកក្នុងរបងធ្វើការបានបែងចែកគ្នាជាក្រុម។អ្នកស្និទ្ធស្នាល ឬសាច់ញាតិគ្នាបានរួមបាយជាមួយគ្នា។មឹងប្រេមបានចូលរង់ជាមួយម៉េង នាងប្រុញក្មួយស្រីគាត់ និងគូលិម្នាក់ទៀត។គេចូលម្ហូបគ្នា។ម្នាក់ៗសុទ្ធតែមានកញ្ចប់បាយ។ម្ហូបក្រៀមក្រោះ មានកូនត្រីប្រឡាក់ ក្ដាមប្រៃ ខ្ទឹមប្រៃ ប្រហុកអំបិល។គេស៊ីត្បិតត្បៀតណាស់។គេស៊ីម្ហូប គេស៊ីបាយច្រើន។គេស៊ីឲ្យតែធ្ងន់ពោះ ព្រោះម្ហូបគេមិនមែនបានផ្ដល់ឲ្យគេមានសុខភាពអាយុវែងទេ។គេស៊ីឲ្យតែរស់សម្រាប់កាប់គាស់ថ្ងៃរសៀល ...ថ្ងៃស្អែកទៀត...។ស៊ីរលើបរលោប រហេមរហាមនេះបានធ្វើឲ្យគេអស់កម្លាំងឆាប់ ព្រមនិងបណ្ដុះស្មារតីឲ្យគេត្រិះរិះដោះទុក្ខវេទនារបស់គេ។លក្ខណ:សម្បត្តិនៃការរស់នៅជាមេកំណត់ស្មារតីរបស់មនុស្ស។ម្ល៉ោះហើយគូលិទាំងនោះ ទាំងត្រូវទាំងខុស ចេះតែបបួលគ្នាជជែករកមធ្យោបាយប្រែការរស់នៅរបស់ខ្លួនឲ្យបានស្រួល ឲ្យបានឆ្អែត។

គេបាយបណ្ដើរ គេជជែកគ្នាបណ្ដើរ។មឹងប្រេមបែបគិតជាងគេ។គាត់រំពៃមើលទៅកូនប្រុសគាត់ដែលមានអាយុ៥ឆ្នាំ ហើយដែលគាត់ដាក់ឲ្យវាដេកនៅបៀតនោះ។គាត់យកក្រមាបក់ដេញរុយឲ្យវាម្ដងៗ បន្ទាប់មកគាត់បាននិយាយ៖

- ធ្វើការហត់ណាស់ ញើសជាទឹក បានស៊ីមិនឆ្អែត បានព្រឹកខ្វះល្ងាច លិទ្ធអំបិលប្រហុករាល់តែថ្ងៃ មានកម្លាំងឯណាធ្វើការ។
- ប្រាកដហើយ...! (ម៉េងបន្ថែម...)។
- ស្រុកយើងឯករាជ្យ សន្តិភាពហើយ គួរតែយើងបានរស់ស្រួល គួរតែយើងស៊ីឆ្អែត គួរតែយើងបានធូរ។ (ម្នាក់បានបន្ត...)។
- គ្មាននរណាស្គាល់ទុក្ខយើងជាងយើងទេ មានតែក្រុមយើងទេដែលអាចដោះទុក្ខយើង។ខ្លួនទីពឹងខ្លួន។ យើងជាគូលិមិនខុសពីសត្វគោនោះទេ។គេចិញ្ចឹមយើងឲ្យគ្រាន់តែរស់ដើម្បីគេប្រើថ្ងៃស្អែកទៀត ...។ (ម៉េងបាននិយាយ)។

- ចុះអ្នកហ៊ីឯង បានធ្វើគូលីប៉ុន្មានឆ្នាំហើយៗ មានសល់កាក់ខ្លះទេ? (មីងប្រេមបានសួរទៅគូលីម្នាក់ទៀតដែលបាយជាមួយ ហើយដែលមានមាឌមាំ សក់រួញអង្កាដី)។
- ខ្ញុំធ្វើគូលីជាងមួយឆ្នាំហើយ។ប៉ុន្មានខែមុននេះ ខ្ញុំបានចូលធ្វើគូលីនៅបៀតវត្តភ្នំ ធ្វើផ្ទះបុណ្យពិព័រណ៍។
- ធ្វើស្រួលឬទេនៅទីនោះ?
- ស្រួលមិនកើតទេ! ស៊ីមិនគ្រាន់ដូចតែគ្នាអ៊ីចឹង!
- ចុះហេតុអ្វីបានជាឈប់ពីទីនោះ?
- ខ្ញុំទៅសួរកូនខ្ញុំឈឺនៅបាត់ដំណឹង ហើយត្រឡប់មកវិញ គេឈប់យកគូលីទៀត។ខ្ញុំតែលតោលអស់៤-៥ថ្ងៃទើបនឹងសូមធ្វើការបាននៅហាងនេះ...។នាងប្រុញ ក្មួយស្រីមីងប្រេមបានផ្ទៀងស្ដាប់ ហើយក៏សួរដោយឆ្ងល់ថា៖
- នៅគ្រប់កន្លែងធ្វើការគូលីស៊ីដូចគ្នាឬ?រស់នៅដូចគ្នាឬ?
- មិនដូចគ្នាទេ។ (នាងម៉េងឆ្លើយ)។គូលីត្រាវ៉ូស៊ីបានមួយថ្ងៃ១២រៀលនៅខេត្តក្រៅ។នៅទីក្រុងស៊ី១៥រៀល ឬ១៨រៀលតាមភេទប្រុសស្រី តាមចាស់ក្មេង។គូលីហាងក៏ស៊ីមិនដូចគ្នាដែរ។ដូចពួកយើងនេះមានស៊ីតាំងពី១៨រៀល ទៅ២២រៀល តាមអាយុក្មេងចាស់ និងតាមធ្វើការយូរឆាប់។នៅកន្លែងបូមដីគូលីមានស៊ីដល់ទៅ៣០រៀលមួយថ្ងៃ។

គូលីស្ទើរគ្រប់រូបបានស៊ីការ៉េម និងនំបញ្ចុកជឿ។ម្ល៉ោះហើយ ក្រោយពីបើក “ប្រាក់ឈ្នួលដាច់ពោះ” នេះ គូលីតែងតែត្អូញប្រាប់គ្នា។មីងប្រេមបានថ្ងូរប្រាប់ម៉េង និងហ៊ី៖

- ខ្ញុំអាទិត្យនេះជំពាក់នំបញ្ចុក២០រៀល ចឹកការ៉េម៥រៀល។ខ្ញុំខំអត់សំចៃណាស់តែអស់កម្លាំងពេក ធ្វើការអស់កម្លាំងពេកទ្រាំសុំផងមិនបាន...។

ហ៊ីបានបន្ថែម៖

- មិនមែនតែមីងម្នាក់ឯងទេជំពាក់នោះ ធ្វើការម៉្ងៃៗញើសជាទឹក យើងគ្រប់គ្នារវល់តែឲ្យទៅចឹកការ៉េម មីងលក់នំបញ្ចុក។

មិនស្របយោបល់នេះ ម៉េងបានបំភ្លឺ៖

- នឿយជិតស្លាប់មិនស៊ីខ្លះ បានកម្លាំងឯណាធ្វើការ... ចឹក និងមីងនំបញ្ចុកនោះក៏មិនឃើញចំណេញឯណាច្រើនដែរ ឃើញតែរស់នៅត្រដាបត្រដួសដូចយើងអ៊ីចឹង ហើយខំក្រោកស្លតាំងពីមាន់រងាវ ឯងរែកកប់ស្វា រែកយកមកឲ្យយើងបន្តកម្លាំង ...។យើងខ្វះមុខ ខ្វះក្រោយស៊ីមិនឆ្អែត គឺមកពីយើងបានប្រាក់ឈ្នួលថ្លៃតិចពេក...។ហាងបានគែយកចំណេញពីយើងជាងពាក់កណ្ដាល។ដឹងទេ ហាងទិញពីយើង១០រៀល យកទៅលក់ឲ្យរាជការជាងម្ភៃរៀល។រឿងជីកឫសផ្ទះនេះ ជាក់ស្ដែងណាស់ ហាងម៉ៅឲ្យយើង១ម៉ែតគូបតែ១០រៀល ហើយយកទៅលក់ឲ្យរាជការ២២រៀល។ឃើញទេ យើងធ្វើការ៨ម៉ោងមួយថ្ងៃ គេឲ្យយើងតែថ្លៃឈ្នួលបួនម៉ោងទេ ...។

ហ៊ីបានស្ដាប់ឈប់ប្រកែក។គាត់បែរលើកម៉េងថា៖

- ថ្ងៃមុនបងម៉េងឯងបានប្រាប់យើងថា ទៅលេងស៊ឹមគួកនបងឯងសួរពីការរស់នៅស្រុកនានាថ្ងៃណា យើងទៅបាន...។
- បើមីង បើបងហ៊ុឺងឯងទំនេរ យើងទៅយប់នេះ...។

## ៤- រាត្រីថ្ងៃសៅរ៍

យប់ខែងាច់ងងឹតចាក់ភ្នែកមិនធ្លុះនៅខាងក្រៅ។ក្នុងផ្ទះតៀមមួយដែលមានទំហំ៥ម៉ែតបណ្តោយ ៣ម៉ែតទទឹង ចង្កៀងប្រេងកាតតូចមួយបានបំភ្លឺមិនសូវច្បាស់ មនុស្សបួននាក់អង្គុយជំកង់លើគ្រែប្ញស្សី។មនុស្សនោះគឺ មីងប្រេម ម៉េង ហ៊ី និងស៊ឹម។ស៊ឹមជាម្ចាស់ផ្ទះ គាត់ជាអ្នកបរឡាន។ស៊ឹមបានស្គាល់ម៉េងកាលនៅបើកឡានឲ្យហាង ហើយកាលនោះម៉េងធ្វើគូលីតាមឡាន។ពិតមែនតែស៊ឹមចេញមកបរឡានរាជការ អ្នកទាំងពីរនៅតែទៅមករកគ្នា រាប់អានគ្នាយ៉ាងជិតស្និទ្ធ។

ផ្ទះស៊ឹមគ្មានតុ ទូ កៅអីអ្វីទេ ក្រៅពីគ្រែប្ញស្សីដែលអ្នកទាំងបួនបានអង្គុយជំកង់លើ និងគ្រែដេកមួយទៀត។ នៅលើធ្នើរជញ្ជាំងមុខ គេឃើញមានសៀវភៅអធិប្បាយវជ្ជធម្មនុញ្ញ ទំនៀមទំលាប់ និងច្បាប់ខ្មែរ ប្រវត្តិអាចារ្យហែមចៀវ កាសែតសាមគ្គី ប្រជាជនប្រជាជាតិខ្មែរ ខ្មែរថ្មីទៅមុខ ចងជាបាច់រៀបមានសណ្តាប់ធ្នាប់យ៉ាងល្អ។ស៊ឹមជាអ្នកចង់ចេះដឹង ចង់ដឹងមើលច្រើន។

យប់នេះគេប្រជុំគ្នាផឹកតែ។អ្នកទាំងបួនបានជជែកគ្នាសួរពីនេះ ពីនោះ សុខទុក្ខយូរបន្តិចមក ម៉េងបានផ្តើមថា៖

- ធ្វើការស្រួលទេស៊ឹម?
- មិនសូវជាពិបាកទេ តែតឹងទ្រូងណាស់...
- ឯងបានប្រាក់ខែច្រើន...
- ច្រើនមិនកើត។ខ្វះរាល់ខែ។ប្រពន្ធខ្ញុំទៅស្រែជួញអង្ករបាត់ហើយ ដើម្បីយកមកជួយទប់។បើកឡានត្រូវចេញទៅមុន ត្រឡប់មកក្រោយគេ។ខ្ញុំខ្លាញ់ធុញនឹងជូតដានជើងស្រីៗ។
- ចៅហ្វាយស៊ឹមឯងស្រីឬ?
- នៅតែឆ្ងល់ទៀតម៉េងឯង។ចៅហ្វាយខ្ញុំគាត់ដើរលេងយប់ បឹងស្នោ បាកំប៉ាយ ហើយព្រលឹមឡើងខ្ញុំត្រូវជូតដានជើងទាំងអស់។
- ស្គាល់ហើយបឹងស្នោនោះ តែអាបាកំប៉ាយវាស្អីដែរ?
- អាហ្នឹងក៏ដូចជាបឹងស្នោដែរ នៅបៀតកន្លែងចាក់សំរាមដេប៉ូ។អាស្នោ និងអាកំប៉ាយនោះ វាមានក្លិនដូចតែអាសំរាមដេប៉ូអីចឹង។តែនឹកឃើញរឿងអស់នេះ ចង់តែឈប់ធ្វើការ ខ្ញុំធុញទ្រាន់ណាស់នឹងជូតដានជើងអស់នោះ។

ហ៊ី និងមីងប្រេមបានស្តាប់មើលមុខស៊ឹមមិនដាក់ភ្នែក។ម៉េងឃើញស៊ឹមតូចចិត្តខ្លាញ់ដូចនេះ បានប្រែរឿង៖

- ឈប់និយាយពីរាត្រីថ្ងៃសៅរ៍ បឹងស្នោ ឬបាកំប៉ាញទៅ យើងមកយប់ថ្ងៃសៅរ៍នេះមានបំណងធំចង់ឲ្យស៊ឹមឯង ដែលជាអ្នកមើលសៀវភៅ កាសែតច្រើន ពន្យល់យើងអំពីការរស់នៅនៃគូលីនៅ ប្រទេសនានាក្នុងលោក។តើកម្មករស្រុកគេវេទនាដូចយើងដែរឬ ? តើគេទិញមនុស្សប្រើខួបដូចយើងដែរឬ?

- ខ្ញុំមិនសូវដឹងជ្រៅជ្រះទេរឿងប្រទេសគេ។តែខ្ញុំបានសួរគេឯង មើលកាសែតបានដឹងខ្លះ។ខ្ញុំនិយាយកាត់ៗបានខ្លះ តែបើបងប្អូនបានឮដំណឹងប្លែក ជួយកែតម្រង់ផង។

ដល់ត្រឹមនេះ ស៊ីមបានឈប់ក្រែបតែលាងបំពង់ក រួចគាត់ចាប់និយាយតះ

- សកលលោកសព្វថ្ងៃ ចែកជាពីរផ្នែកៈ ផ្នែកសង្គម និងចក្រពត្តិនិយម។នៅផ្នែកសង្គមនិយម បើយើងជឿសេចក្ដីថ្លែងការណ៍របស់អ្នកនយោបាយចំណានៗនៅទ្វីបអាស៊ី យើងមុខជាជ្រាប់បានថា នៅប្រទេសនោះការកសាងសេដ្ឋកិច្ចបានចម្រើនរហ័ស។កម្មករ គូលីបានធ្វើជាម្ចាស់នៃការងាររបស់ខ្លួន មានសមាគម មានសហជីពជួយដឹកនាំពួកកម្មករគូលី ឲ្យចេះតស៊ូទល់នឹងធម្មជាតិ បង្កើនផលដើម្បីកែប្រែ និងលើកតម្កើងការរស់នៅឲ្យបានខ្ពស់សុចរិតយុត្តិធម៌។នៅផ្នែកចក្រពត្តិវិញ ការរស់នៅប្រជាជនមានច្រើនជាន់ខុសគ្នាណាស់។អ្នកណាមានស៊ីៗមិនអស់ រឹតតែមានឡើង ហើយអ្នករហេមរហាមរឹតតែរហេមរហាមទៅ។នៅប្រទេសអាមេរិច សព្វថ្ងៃប្រជាជនជាង៤លាននាក់គ្មានការធ្វើហើយរស់នៅយ៉ាងវេទនា។តែដោយការទាមទារដ៏អង់អាចរបស់កម្មករនៅប្រទេសចក្រពត្តិធំៗ បារាំង អង់គ្លេស អាមេរិច កម្មករមានសិទ្ធិផ្តុំគ្នាជាសមាគម ជាសហជីព រើសតំណាងឲ្យទៅតវ៉ាទាមទារប្រាក់ឈ្នួលឲ្យបានស៊ីគ្រប់គ្រាន់ និងមានកម្រិតម៉ោងធ្វើការ កុំឲ្យហួសពី៤៨ម៉ោងមួយអាទិត្យ។ដូចនេះបានជាយើងបានដំណឹងរាល់ខែ រាល់អាទិត្យថា នៅប្រទេសចក្រពត្តិធំៗទាំងនោះ កម្មករមានអ្នកបើកឡាន ជាងតម្បាញទាំងពាន់ ទាំងម៉ឺន ទាំងសែននាក់បានធ្វើកូដកម្ម បាតុកម្មទាមទារប្រាក់ឈ្នួលឲ្យបានស៊ីគ្រប់គ្រាន់។

មីងប្រេមបានសួរកាត់ះ

- ស្រុកយើងពួកគូលី ពួកជាងធ្វើសមាគមបានទេ?មនុស្សរស់ច្រើនណាស់សព្វថ្ងៃ។
- ស្រុកយើងឯករាជ្យ ប្រជាធិបតេយ្យត្រូវតែមានអំណាចផ្តុំគ្នាធ្វើសមាគមបាន។តែនៅបែកខ្ញែកគ្នាណាស់។បើចង់កែប្រែការរស់នៅ ធ្វើជាម្ចាស់ការងាររបស់យើង ទាល់តែយើងបង្កើតសមាគមវិជ្ជាជីវៈ។
- បើដូចនេះ ត្រូវធ្វើដូចម្ដេច? មីងប្រេមសួរ។
- រួបរួមសាមគ្គីរវាងគ្នាយើងយ៉ាងជិតស្និទ្ធ ដើម្បីរៀនសូត្រដើម្បីប្រមូលផ្តុំគ្នាជាសហជីព ជាសមាគម..។
- រៀនម្ដេចបាន បើធ្វើការអស់កម្លាំងជិតងាប់ម្ល៉េះ ហើយអាយុជាង៤០ហើយ។មីងប្រេមបានប្រកែក។
- មិនជាអ្វីទេ ប្រពន្ធខ្ញុំទើបតែចាប់រៀន ក ខ ដែរ។ត្រូវឆ្លៀតរៀនពេលសម្រាកថ្ងៃ សម្រាកយប់ អក្សរមួយតួ ពីរតួ។សួរម៉េង សួរបងហ៊ី។បើយើងព្យាយាមមិនហួសពី៦ខែទេ យើងមើលកាសែតបាន។

ម៉េងបានសង្កត់ពាក្យស៊ីមះ

- ស្រុកយើងថ្កើន ទាល់តែពួកយើងថ្កើន ទាល់តែពួកយើងប្រឹងប្រែងការរស់នៅខ្លួនយើង។យើងត្រូវខំរៀន។

និយាយដល់ត្រង់នេះ នាឡិកាផ្ទះថ្មធំមុខបានទូង១១ម៉ូង ហ៊ីកេះម៉េងប្រាប់ថាល្ងមហើយ។ម៉េងក៏និយាយត
៖

- យប់ជ្រៅហើយ យើងល្ងមលាស៊ឹម ចាំថ្ងៃណាទំនេរមកទៀត។ហ៊ីត្រូវការខ្ចីសៀវភៅស៊ឹមខ្លះទេ?
- ខ្ញុំចង់មើលប្រវត្តិអាចារ្យហែមចៀវ។
- យកចុះ តែកុំឲ្យបាត់ ព្រោះក្រណាស់។សូមអញ្ជើញមកជជែកគ្នាលែងគ្នាទៀត ថ្ងៃក្រោយប្រពន្ធខ្ញុំមុខជាត្រឡប់មកពីស្រែវិញ។

# ៥- ចាំលោក

- ស៊ីមឥឡូវមិនសូវនឿយហត់ទេ។ម៉ោងជិត៨បានមកដល់។ពូសនបាននិយាយទៅកាន់ស៊ីម ក្រោយដែលស៊ីមបានចតរទេះឡាននៅបៀតឡានគាត់ ហើយដើរមកអង្គុយជាមួយគាត់។
- ចាំមិនយ៉ាប់ចុះ ស៊ីមឆ្លើយ រាល់ថ្ងៃចេញពីផ្ទះម៉ោង៦ ទៅដល់ផ្ទះលោកម៉ោង៦កន្លះ ជូនកូនលោកទៅរៀន រួចត្រឡប់មកជូនលោកមកធ្វើការ។
- កូនលោកទៅរៀនសាលាណា?
- រៀនសាលាបារាំងបៀតវត្តភ្នំ។
- ខ្ញុំមានកូនមួយដែរ វាប្រឡងជាប់សញ្ញាប័ត្រ តែប្រឡងចូលវិទ្យាល័យធ្លាក់។ឥឡូវមិនដឹងឲ្យទៅរៀនឯណាទេ។ប្រាក់ខែមិនគ្រប់គ្រាន់សោះ។មីងឯងចងការលុយគេចាយរាល់តែខែ ពិបាកណាស់...។
- ខ្ញុំក៏អីចឹងដែរ។ខ្វះព្រឹក ខ្វះល្ងាច។ឲ្យប្រពន្ធទៅស្រែលក់អង្ករគ្រាន់នឹងទប់។
- ពូសង្ឃឹមលើឆ្នោតណាស់សព្វថ្ងៃ។រាល់ថ្ងៃអាទិត្យ ពូទិញឆ្នោត៣សន្លឹក តែវាមិនដល់ម្តងសោះ។ឲ្យតែត្រូវចំហុកសិបម៉ឺន ពូមុខជាសង់ផ្ទះ ហើយឲ្យកូនទៅរៀនសាលាឈ្នួលទៀត...។
- ខ្ញុំឈប់ចាប់ឆ្នោតផ្សងសំណាងជាងមួយឆ្នាំហើយ។អស់ជាងពីរឆ្នាំ ខ្ញុំបានប្រព្រឹត្តលេងឆ្នោតរាល់អាទិត្យ តែវាមិនដែលបៀតមួយលេខសោះ។មួយខែៗចាយទៅឆ្នោតជិត១០០រៀល។ជញ្ជាំងខ្ទមខ្ញុំពេញទៅដោយសន្លឹកឆ្នោតជាតិ...។
- ចំណែកពូមិនដែលត្រូវសោះមែន តែមីងឯងដូចជាហេងជាងពូ គេត្រូវបានពីរលើកមួយពាន់ៗរៀល។ហេតុនេះហើយបានជាពូមិនទាន់អស់សង្ឃឹម ពូល្បងលេងទៀត...។
- ខ្ញុំស្បថឈប់លេងហើយ។ខ្ញុំសន្សំលុយនោះយកទៅប្រើការផ្សេងវិញ។មួយខែជិត១០០រៀល។
- យើងមិនចូលផ្លូវគ្នាទេ។ពូនៅតែលេងឆ្នោតជានិច្ច។មើល តើឯងសន្សំទុកដូចម្តេចកើត បើខ្វះច្រករាល់តែខែដូចនេះ។
- ខ្ញុំចាយលុយនោះទិញសៀវភៅល្អៗយកមករៀន ខ្ញុំជាវកាសែតមើល...។
- រៀនខ្មោចអី ចំណាស់ស៊ីមឯងហើយ។វាអស់បានធ្វើលោកអ្នកនឹងគេហើយ ធុនយើងនេះ។
- ខ្ញុំគ្មានចង់ធ្វើលោក-អ្នកទេ។ខ្ញុំចង់តែចេះដើម្បីឆ្ពោះទៅរកផ្លូវយុត្តិធម៌តែប៉ុណ្ណោះ។ខ្ញុំចង់ចេះដើម្បីការពារសិទ្ធិសេរីភាពខ្ញុំ កុំឲ្យគេបំពាន។ខ្ញុំចង់ចេះដើម្បីជួយពង្រឹង និងពង្រីកអព្យាក្រឹតភាព ឯករាជ្យប្រជាធិបតេយ្យប្រទេសយើង...។
- ទាវាមិនដែលឡើងរានទេស៊ីមអើយ ជឿពូចុះ។ពូបើកឡានតាំងពីជំនាន់បារាំងមក មិនដែលឃើញអ្នកបើកឡានណាឆ្កួតដូចស៊ីមឯងទេ គិតមើលកាសែត គិតរៀននោះទេ... ឯងកុំចង់ចេះពេក ព្រោះអ្នកចេះមិនស្រួលទេ។
- ហេតុអ្វីក៏ដូចនោះ?

- តែចេះវារបេះក្បាច់។អាចារ្យហែម-ចៀវ វ័ណ្ណកដោយសារចំណេះទេតើ។ឯងមិនចាំទេ បារាំងនិរទេសទៅកោះត្រឡាច ចោលឆ្អឹងនៅកោះកណ្ដាលសមុទ្រ...
- នោះជាន់ដើម យើងចំណុះបារាំង...។
- ចុះឥឡូវ គ្មានគុកឬ? ចាងហ្វាងកាសែតច្រើនណាស់ សុទ្ធតែចេះអធិប្បាយក្បោះក្បាយដែរ...។អ្វី! ពូមិនចាំបាច់និយាយវែងទេ ឯងដឹងស្រាប់ហើយ។
- ពូថាឲ្យអស់ទៅមើល។
- តើនៅគុកប៉ុន្មានខែ ម្នាក់ៗ? ឯងចាំទេ?
- បើដូចនេះ ចង់ឲ្យកូនពូឯងរៀនចេះធ្វើអ្វី? ចាំបាច់គិតព្រួយពីគ្មានសាលាឲ្យវារៀនធ្វើអ្វី?

ត្រង់ពាក្យសួរនេះ ពូសនបែបទាល់ហើយក៏បែរមើលមុខស៊ឹម សួរតបមកវិញ៖

- មើលឯង បានរៀនអ្វីខ្លះ? ឯងមើលកាសែតអ្វីខ្លះ?
- ខ្ញុំ ពីដើមជាវកាសែតសាមគ្គី ប្រជាជន ខ្មែរថ្មីទៅមុខ។បន្ទាប់មកខ្ញុំជាវកាសែតប្រជាជាតិ ប្រជាធិបតេយ្យ។លោកខ្ញុំឲ្យកាសែតសង្គមរាស្ត្រនិយមខ្ញុំមើល ឥឡូវខ្ញុំមើល "វត្តភ្នំ"។
- ស៊ឹមឯងហ៊ានមើលកាសែតប្រជាជាតិ ប្រជាធិបតេយ្យ ប្រជាជនផង នៅស្រុកស្រែចំការ ឮគេថា គេហាមមិនឲ្យមើលកាសែតអស់នោះទេ។គេដៅសម្គាល់អ្នកមើល ស៊ឹមឯងប្រយ័ត្ន...។
- ខ្ញុំគ្រាន់តែឮ តែខ្ញុំមិនទាន់ឃើញនរណាហាមម្ដងសោះ ក្រៅពីពូឯងបំភ័យខ្ញុំនេះ ក្នុងការធ្វើអ្វីក៏ដោយ យើងត្រូវពិនិត្យឲ្យហ្មត់ចង់ មិនត្រូវភ័យជ្រួលគ្មានចុងដើមទេ។
- យើងត្រូវសួរជាមុន តើកាសែតទាំងនោះ នរណាឲ្យច្បាប់ចេញ ក្រែងរាជការឬ? បើដូចនេះ អ្នកដើរបំភ័យមិនឲ្យមើល មានពូសនជាដើម គឺសុទ្ធជាអ្នកបំផ្លាញច្បាប់ សេរីភាព សិទ្ធិប្រជាជនខ្មែរពេញទី។
- កុំចេះពេក។ពូឆាស់រំលឹកទៅ បែរជាចោទថា ពូរំលោភសេរីភាព សិទ្ធិទៅវិញ។ស៊ឹមឯងប្រយ័ត្ន កុំក្អេងក្អាងពេក...។
- ពូសនៗ។បើកឡានមក។សម្លេងមួយបានចេញពីមន្ទីរធ្វើការ។

ពូសនរត់ចូលទៅក្នុងឡាន បញ្ឆេះម៉ាស៊ីន បើកឡានគាត់ទៅអែបជើងជណ្ដើរ បន្ទាប់មកឡានម៉ាកអាមេរិកវែងបានលូនចេញទៅក្រៅ...។

## ៦- ព្រឹកថ្ងៃអាទិត្យ

- ម៉ោងប៉ុន្មានហើយ? មកចាំខ្ញុំយូរហើយឬ? ម៉េងបានសួរទៅស៊ឹមដែលកំពុងតែឈរមើលម៉ាស៊ីនបូមដី នៅត្រង់ផ្លូវបែលហ្ស៊ិក និងផ្លូវស៊ីសុវត្ថិ។
- មកមួយស្របក់ហើយ។ម៉ោង៨ជាងកន្លះហើយ។ព្រឹកនេះមេឃស្រទំជាប់។
- ខ្ញុំមិនឃើតទេ បើដូចនោះ តស់យើង ទៅផ្ទះមីងប្រេម។
- ផ្ទះគាត់នៅឆ្ងាយពីទីនេះឬ?
- នៅឆ្ងាយដែរ។នៅកន្លែងគាត់ធ្វើការឯណោះ។អាទិត្យមុនគាត់នៅខាងលិចម៉ាស៊ីននេះចម្ងាយប្រហែល ២០០ម៉ែត ជាមួយនឹងគូលីរទេះភ្លើងចាក់ដី។ក្រុងយើងត្រូវតុបតែងកាយទទួលជនបរទេស មកមើលបុណ្យ ម្ល៉ោះហើយ មីងប្រេម និងក្រុមគាត់ក៏ត្រូវបែកគ្នាចេញពីទីនេះ...។ណ្ហើយ កុំមើលម៉ាស៊ីនយូរពេក យើងត្រូវឆាប់ទៅ កុំឲ្យមីងប្រេមទន្ទឹងមើលផ្លូវ...។

ថាហើយម៉េង និងស៊ឹមបានឡើងកង់មួយម្នាក់ ជិះតាមផ្លូវបែលហ្ស៊ិកទៅឯជើង ម្ភៃនាទីក្រោយមកគាត់បានចូលទៅក្នុងភូមិមួយ មានផ្ទះពីរខ្នងធំៗ សង់មិនទាន់ហើយ។ម៉េងបាននាំស៊ឹមដើរសំដៅទៅពពួកខ្ទមគូលី ហើយចង្អុលប្រាប់ស៊ឹមថាៈ

- ស៊ឹម នេះផ្ទះមីងប្រេម។ឃើញគាត់ទេ កំពុងតែរៀន...។

ម៉េង និងស៊ឹមបានទៅដល់ផ្ទះមីងប្រេម។គេបានសួរសុខទុក្ខគ្នារួចហើយ មីងប្រេមអញ្ជើញភ្ញៀវឲ្យចូលទៅក្នុងខ្ទមគាត់ដែលចុះតែកូនគ្រែតូចមួយ។គ្រែនេះជាកន្លែងដេករបស់មីងប្រេម នាងប្រុញ និងអាប្រាជ្ញកូនតូចគាត់។ គ្រែនេះជាកន្លែងទទួលភ្ញៀវ ហើយនៅពេលភ្ញៀវចេញ គ្រែនេះក៏ក្លាយទៅជាកន្លែងបាយទៀត។នៅក្រោមគ្រែមានឆ្នាំងដី ពាងក្រឡ លាយឡំចម្រុះនឹងចានគ្រើមបីបួន។មីងប្រេមបានហៅនាងប្រុញឲ្យយកអាប្រាជ្ញមកឲ្យគាត់ ហើយបង្គាប់ឲ្យរកថ្នាំជាក់ជូនម៉េង និងស៊ឹម។បន្ទាប់មកគាត់និយាយៈ

- ស្មានតែមិនអញ្ជើញមក ខ្ញុំចាំមើលផ្លូវតាំងពីព្រឹក...។
- មិនមកឯណាបាន ខ្ញុំនឹកមីងណាស់។ស៊ឹមបានតប។មីងរៀនចេះច្រើនហើយ មើលទៅបែបខស្បាហ៍... ។
- មិនទាន់ចេះទេ ទើបតែរៀនដល់បំបែក។តាំងពីខ្ញុំស្ដាប់អ្នកនិយាយយប់ថ្ងៃសៅរ៍មក ខ្ញុំបានឆ្លៀតរៀនជាប់។នាងប្រុញក្មួយខ្ញុំមើលសៀវភៅជាច់ខ្លះ វាបានរៀនដល់ថ្នាក់ទីពនៅស្រុកខ្ញុំ។រាល់យប់វាបានដាក់ច្បាប់ឲ្យខ្ញុំ... ខ្ញុំរៀនទៅទៀត។
- យើងដើរផ្លូវត្រូវហើយ។ម៉េងបានបន្ថែម។
- វិញ្ញាណខ្ញុំ វាមិនមូលក្នុងការរៀនសូត្រសោះ។វាប្រេះបែកខ្ទេកមួយរយជំពូក។មីងប្រេមបានថ្លែងទុក្ខ។ ខ្ញុំពិបាកជាប់ ព្រួយជាប់ ពិបាកកាយ ដោយខ្ញុំមិនសូវជាពិបាកចិត្តដោយមិនដឹងជាទៅនៅឯណាប្រាកដ ដល់អស់ការធ្វើនៅទីនេះ។
- មីងគ្មានបងប្អូនទេឬ នៅភ្នំពេញ? ស៊ឹមបានសួរ។

- មានដែរ តែឯងក្រមិនហ៊ានទៅបៀតគេឡើយ។អាប្រាជ្ញកើតមកបានជិតមួយខួប ប្ដីខ្ញុំត្រូវគ្រាប់ស្លាប់នៅឱកាសដែលបារាំងទៅព័ទ្ធភូមិដុតផ្ទះអស់ពីរខ្នង។អាកូនបងខ្ញុំបាន១៨ឆ្នាំ ពេលនោះភ័យពេក វត់បាត់ទៅ មិនដឹងជាស្លាប់ឬរស់ទេ។ខ្ញុំចេញពីភូមិកំណើតជិតបួនឆ្នាំហើយ... ពិបាកណាស់នៅស្រែនោះ...។
- មកភ្នំពេញមីងនៅឯណា?
- ខ្ញុំនៅស៊ីឈ្នួលគេក្នុងគ្រួសារ។ខ្ញុំបម្រើគេ យកតែបាយចិញ្ចឹមអាប្រាជ្ញខ្ញុំ កាលនោះវាមានអាយុជាងមួយខួប។
- មីងចេញមកធ្វើគូលីហាងយូរហើយ?
- ចាស៎ ជាង៦ខែហើយ។តាំងពីមីក្មួយខ្ញុំនេះ វាមកនៅជាមួយ។មីនេះ ម៉ែឪវាស្លាប់ចោលអស់ទៅ រកអ្វីរៀនគ្មាន បានជាវារត់មកនៅជាមួយខ្ញុំ។វាទើបតែបានអាយុ១៣ឆ្នាំ...។ពិបាកណាស់ឯងក្រនោះ។គ្មាននរណាមើលឃើញឡើយ។ឥឡូវខ្ញុំនៅតែសម្បុកខ្លួនប៉ុណ្ណឹងទេ។ថ្ងៃណាឈឺធ្វើការមិនកើត មុខជាដាច់ពោះហើយ។មិនដឹងជារកស៊ីអ្វីឲ្យបានសល់ទុកដាក់នឹងគេឡើយ ធ្វើការញើសជាទឹក នៅតែខ្វះជានិច្ច។មួយរៀលច្រៀកជាមួយរយចំរៀក នៅតែខ្វះទៀត។ប្រាក់បើកថ្ងៃសៅរ៍មិនដែលសល់ដល់អង្គារទេ។ទំនិញសព្វគ្រប់ឡើងថ្លៃ...។បើចេះតែយ៉ាប់ទៅៗដូចនេះ តើយ៉ាងណាទៅ។ណាអាណិតមីប្រញមិនទាន់ដល់អាយុផង ក៏ខំមកកាប់ជញ្ជូនដីនឹងគេ។
- មានតែយើងទេដែលចេះស្គាល់ទុក្ខវេទនាក្រុមយើង។ស៊ឹមបានកាត់។
- មានអ្នកចេះ អ្នកធំ អ្នកមានខ្លះដែរកាន់ជើងយើង។ម៉េងបានបន្ថែម។
- មានអ្នកចេះ អ្នកធំ អ្នកមានខ្លះដែរ តែចំនួនតិចតួចណាស់។ស៊ឹមបានប្រកែក។សំខាន់គឺយើងត្រូវពឹងលើកកម្លាំងយើង ដូចជានៅក្នុងកន្លែងធ្វើការនេះដែលមានគូលីជាប់១០០នាក់ យើងត្រូវចាត់តាំងបង្ហាត់បង្រៀនគ្នាឲ្យចេះរៀនសូត្រ ឲ្យចេះមើលកាសែត។នៅស្រុកប្រជាធិបតេយ្យពិតប្រាកដ ក្នុងហាងដូចជាយើងនេះ សុទ្ធតែមានសមាគម ឬសហជីពការពារក្រុមអ្នកធ្វើការ ហើយដឹកនាំអ្នកធ្វើការឲ្យចេះការពារកម្លាំងរបស់ខ្លួន...។រាល់ជាង រាល់គូលី សុទ្ធតែបានមើលកាសែតចេះដឹងរឿងនយោបាយក្នុងស្រុក និងក្រៅស្រុក...។
- ក្រជិតងាប់ មាត់ជិតស្លាប់ មានលុយមានពេលឯណាទិញកាសែតមើល។មីងប្រេមបានប្រកែក។
- បើម្នាក់ៗស្ម័គ្រចិត្តសន្សំប្រាក់កាក់មួយអាទិត្យ ចូលទិញកាសែតក្នុងកន្លែងយើងនេះ យើងអាចទិញកាសែតមួយថ្ងៃៗបានពីរសន្លឹក ហើយនៅសល់ទិញសៀវភៅចែកគ្នាមើល ឬជួយអ្នកឈឺថ្កាត់ខ្លះទៀតផង...។
- យើងកំពុងតែគិតដែរ រឿងនេះ។ម៉េងបានតប។ឥឡូវជាង និងគូលីចូលចិត្តនិយាយពីការរស់នៅ ពីសមាគមណាស់...។បើស៊ឹមឯងចង់ស្គាល់ពួកយើងប្រែខុសពីដើមយ៉ាងណា សូមមកលេងថ្ងៃធ្វើការ ពេលនេះកាន់តែថ្ងៃហើយ យើងល្ងមលាមីងប្រេម។

ស៊ីមបានចោលភ្នែកមើលនាឡិកាដៃ គាត់លោជាភ្ញាក់លាន់មាត់ថា "យី ម៉ោងជិត១១ហើយ ថ្ងៃហើយ តស់យើងទៅម៉េង! ថ្ងៃក្រោយសឹមជួបទៀត តែសូមមីងបន្តការរៀនសូត្រទៅទៀត។ស្រុកយើងចម្រើន ទាល់តែមីង ទាល់តែយើងទាំងអស់គ្នាមានផ្ទះ មានសម្លៀកបំពាក់គ្រប់គ្រាន់ឡើង" ។

# ៧- ចាំលោក

"រត់ស្រួលទេ ឡានពូ" ស៊ឹមបានសួរពូសន ក្រោយដែលពូសនចុះពីឡានមកអង្គុយបៀត។

- អែមលែងនិយាយ។
- ខ្ញុំនៅតែអាបរ្សិបកញ្ចាស់ដដែល។ជុះជូទៗរាល់ពេល នៅតែពុម៉ាស៊ីនទៀត បែបឡោកហើយមើលទៅ។
- ឈប់និយាយពីឡានទៅ។ថ្ងៃមុនស៊ឹមឯងបានប្រាប់ខ្ញុំពីការរៀនសូត្រ តែលោកត្រូវចេញទៅក្រៅ យើងក៏បានបែកគ្នាទៅ។មើលមានដំណឹងអ្វីប្លែក ប្រាប់ពូផង។ពូលែងត្រូវឆ្នោតសោះតែម្តង។
- មានដំណឹងល្អជាទីសង្ឃឹមណាស់ ថ្មីៗនេះ។សព្វថ្ងៃនេះ សកលលោកយើងមានពីរផ្នែកធំៗ ផ្នែកកុំមុយនីសបានសុខចិត្តគោរពបញ្ចសីលាដែលមានគោលសំខាន់ៗដូចតទៅនេះ៖

  ១_ គោរពអធិបតេយ្យភាព និងទឹកដីទៅវិញទៅមក។

  ២_ មិនរុករានគ្នាទៅវិញទៅមក។

  ៣_ មិនជ្រៀតជ្រែកចូលក្នុងកិច្ចការខាងក្នុងប្រទេសណាមួយ។

  ៤_ ពង្រីកការទាក់ទងនឹងស្រុកនានាតាមគោលការណ៍ស្មើមុខគ្នា ហើយដោយបានអនុលោមទៅតាមផលប្រយោជន៍រៀងៗខ្លួន។

  ៥_ រស់នៅជិតខាងគ្នាតាមសន្តិវិធី។

ឯផ្នែកចក្រពត្តិអាមេរិកកាំងជាមេ មិនព្រមគោរពសីលប្រាំនេះទេ។នៅចន្លោះផ្នែកពីរធំៗនេះ មានប្រទេសអព្យាក្រឹត ឥណ្ឌា ភូមា... សុខចិត្តគោរពសីលប្រាំនេះ...។

- ម្តេចក៏ស៊ឹមឯងនិយាយដូចនេះ? ខ្ញុំឮយូរហើយថា អាមេរិកមកជួយខ្មែរ។មើលស៊ឹមឯងដឹងអ្វីប្លែកខុសពីពូដឹង...។
- ពូគិតតែផ្សងសំណាងចង់ត្រូវឆ្នោតបានតែអីចឹង មិនព្រមតាមដានស្ថានការណ៍ស្រុកសោះ។
- កុំនិយាយពីឆ្នោតទៀត។ពូញៀនលេងឆ្នោតដូចលេងបៀរអីចឹង មើលស៊ឹមឯងប្រាប់ពូឲ្យដឹងច្បាស់ពីនយោបាយខ្មែរយើងសព្វថ្ងៃ។
- ប្រជាជនខ្មែរប្តេជ្ញាដើរតាមមាគ៌ានយោបាយអព្យាក្រឹត តែពួកចក្រពត្តិគេមិនទុកឲ្យយើងដើរស្រួលនៅសុខទេ។ពូមិនបានឮទេឬ ថ្មីៗនេះ ប្រទេសហ្វីលីពីនដែលជាសមាជិករង់ សេ អា តូ បានអូសទាញខ្មែរយើងឲ្យចូលដៃជាមួយគេ។
- ស្អីទៅ សេ អា តូ នោះ។ពូមិនសូវដឹង ប្រាប់ពូឲ្យអស់សង្ស័យមើល។
- សេ អា តូ ជាអង្គការការពារអាស៊ីប៉ែកអាគ្នេយ៍ដែលពួកអាមេរិក បារាំង អង់គ្លេស បង្កបង្កើតឡើង។ គេបានក្តាប់ដៃហ្វីលីពីននៅក្បែរៗយើងនេះ។ចំពោះសេ អា តូ នេះ អ្នកនយោបាយអព្យាក្រឹតចំណាន់ៗបានប្រឆាំងពេញទី ហើយបានចោទសេ អា តូជាអង្គការសង្គ្រាម បំផ្លាញកិច្ចព្រមព្រៀងសឺណែវ

ដែលបាននាំសន្តិភាពមកឲ្យប្រទេសឥណ្ឌូចិន។ថ្មីៗនេះទៀត ពួកវង់សេ អា តូបានបញ្ចេញចង្កូមធ្វើសម យុទ្ធនៅប្រទេសថៃ បាងកក ដើម្បីគំរាមប្រទេសអព្យាក្រឹត។

- ពូមិនដឹងអីចឹងសោះ ពូស្មានតែគេជួយយើងដោយស្មោះត្រង់។
- ជំនួយអាមេរិចជួយតែអ្នកមានធំទេ។ពូមិនដឹងឬ? ហើយឥឡូវ ស្ទើរគ្រប់កាសែតបានដាក់ឈ្មោះវាថា "អាគាំង" "អាគាំង" "អារិក"។
- អាគាំងខូចណាស់តើ។ពូសនលាន់មាត់។បើដូចនេះ យើងត្រូវធ្វើដូចម្ដេច?
- យើងត្រូវប្ដេជ្ញាសាមគ្គីគ្នាយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ជាមួយរដ្ឋសភា ការពារអធិបតេយ្យភាព យើងឲ្យហ្មត់ចត់។មានតែធម៌សាមគ្គីរវាងប្រជាជនយើងគ្រប់ជាន់ថ្នាក់ទេដែលអាចឲ្យយើងនៅជាអ ព្យាក្រឹតបាន។
- ពូសនៗ សម្លេងមួយបានហៅ។

ពូសនស្ទុះរត់ ហើយងាកមកនិយាយទៅកាន់ស៊ឹមថា "លោកចេញទៅក្រៅ ថ្ងៃក្រោយនិយាយគ្នាទៀត" ។

# ៨- ដើរលេង

ស៊ឹមបើកឡានផុតពីរបងមន្ទីរធ្វើការ ក៏សួរទៅលោកគាត់ថា៖

- “តេជគុណអញ្ជើញទៅផ្ទះ ឬទៅខាងណា?” ។
- មេឃស្រទន់ល្អល្ងាចនេះ យើងដើរមើលភ្នំពេញម្ដង។បត់ទៅគីឡូម៉ែតលេខ៦ ស៊ឹម។

ស៊ឹមបើកឡានកាត់មុខបុស្តិ៍ខ្សែល្អួសទៅតាមផ្លូវមាត់ទន្លេ ដល់គីឡូលេខ៦ ជិតហាងបិតស្រាបត់មកវិញ។ មកដល់ផ្លូវប៉ាឆាបារាំង ស៊ឹមបត់មកខាងលិចបរកុងព័ទ្ធចេតិយរូបពីរ រួចក៏បើកតាមផ្លូវក្រោយពេទ្យធំ សំដៅមកត្បូងចូលទៅក្នុងកន្លែងពិព័រណ៌អន្តរជាតិ។ដល់កន្លែងរោងសត្វវត្តភ្នំ ស៊ឹមបើកតិចៗហើយសួរទៅលោក៖

- អញ្ជើញទៅខាងណាទៀតទាន?
- បើកលេងតិចៗបត់ចុះឡើងក្នុងទីនេះសិន។ខ្ញុំចាំជួបគេ។

ស៊ឹមបើកមកដល់ខាងលិចវត្តភ្នំបត់ទៅឯខាងលិច តាមថ្នល់ខាងជើងកន្លែងបារាំងហែលទឹក គាត់ក៏បានសួរលោក៖

- តេជគុណមានឃើញអ្វីប្លែកឬទេ កាលបុណ្យពិព័រណ៌អន្តរជាតិ?
- គ្មានឃើញអ្វីជាចំឡែក ក្រៅពីការប្រឡងរើសរូបស្រីៗទេ។
- តេជគុណយល់ឃើញដូចម្ដេច អំពីរឿងរើសរូបនេះ?
- ចំពោះខ្ញុំ ខ្ញុំគ្រាន់តែសប្បាយភ្នែកដោយបានឃើញរូបស្រីមកប្រឡង។ស៊ឹមឯងមានបានមកមើលទេ។ គេស្លៀកខោអូតទឹក បញ្ចេញគល់ភ្លៅខ្ចី។
- ខ្ញុំបាទគ្មានលុយមើលទេ ខ្ញុំបាទប្រថុយចាយប្រាំរៀល ទិញរូបថតទៅឲ្យប្រពន្ធខ្ញុំបាទមើល។ប្រពន្ធខ្ញុំបាទវាថា កោតតែគេហ៊ានទៅបែរប្រឡងដែរ វាមិនចូលចិត្តទេរបៀបនេះ។វាមិនចង់ទាំងហ៊ានមើលរូបថតផង។ខ្ញុំបាទពន្យល់វាថាស្រុកគេស៊ីវិល័យ ត្រូវពាក់អាវនីឡុងបញ្ចេញសាច់ ត្រូវតុបតែងប្រឡងតាមសៀម អាមេរិច។វាថា វាដើរតាមគេមិនទាន់ទេ។
- ចំណែកអ្នកផ្ទះខ្ញុំ ដូចជាផ្ទុយពីប្រពន្ធស៊ឹមឯង។គេចូលចិត្តប្រជុំគ្នានិយាយពីការប្រឡងណាស់។គេថានាងនេះសមត្រង់នេះ គេថានាងនោះទាស់ត្រង់នោះ។គេថានាងនេះខ្នងកំពិស គេថានាងនោះបញ្ចេញភ្លៅហួសហេតុ ហើយបន្តិចគេថា ចេះថាឯចេះ បន្តិចគេថា ឯចុះ។
- កាសែត “មាតុភូមិ” ក៏បានចុះសំបុត្រជាច្រើនពីរឿងប្រឡងរូបនេះដែរ។យោបល់ខ្លះធ្វើនេះត្រូវ យោបល់ខ្លះទៀតថាមិនត្រូវទេ នាំឲ្យខូចប្រពៃណីបុរាណអស់ហើយ។
- ខ្ញុំមិនបានមើលកាសែតខ្មែរទេ ពាក្យខ្មែរថ្មីៗពិបាកណាស់។ខ្ញុំជាវកាសែតបារាំង មើលវានិយាយពីរោះជាង។
- ចំពោះការប្រឡងរូបនេះ ខ្ញុំបាទបានសួរមីងម្នាក់។គាត់ឈ្មោះប្រេម។គាត់ទៅមករកប្រពន្ធខ្ញុំញឹក។គាត់ជាគូលីសង់ផ្ទះ។គាត់មានយោបល់រឹតតែប្លែកទៅទៀត។គាត់ថានៅស្រុកយើង គេច្រើនតែលើកស្រីក្នុង

ពេលមានលុយ ធ្វើបរក្សាឲ្យល្អ ហើយសុខចិត្តចាយលុយទាំងម៉ឺន ទាំងសែនឲ្យៗឯត្រង់ចំពោះស្រីខ្មែរជាងលាននាក់ ដូចក្រុមគាត់ដែលខំធ្វើការសង់ថ្នល់ ធ្វើស្រែ ក្បាលបែកញើស គេមិនព្រមសរសើរសោះ គេរិតតែបំភ្លេចទៅវិញ។គាត់បាននិយាយថា គួរណាស់តែគេគិតឲ្យប្រាក់ឈ្នួលគាត់ស៊ីគ្រប់គ្រាន់ សង់មន្ទីរពេទ្យ សង់សាលារៀនឲ្យកូនគាត់រៀនផង។

- ប្រាប់គាត់ផងថា កុំឃើញដំរីជុះ ចង់ជុះតាមដំរី បើគាត់ចង់ល្អ ហេតុអ្វីក៏គាត់មិនខំធ្វើបុណ្យពីជាតិមុនឲ្យច្រើនទៅ។កម្មផលពីជាតិមុនទេដែលឲ្យគាត់តោកយ៉ាកនោះ។
- ប្រពន្ធខ្ញុំបាទវាថាមិនមែនមកពីកម្មផលទេ តាំងពីវាចេះអក្សរមើលកាសែតមក វាយល់ថាទុក្ខវេទនារបស់ខ្មែរយើង គឺបណ្តាលមកពីពួកអាណានិគមនិយមជិះជាន់យើង។

ដល់ត្រង់នេះ ឡានមួយឲ្យសម្លេងពីតៗពីខាងក្រោយ។លោកងាកមើលទៅ ឃើញអារូមែលមួយខ្មៅរសិល។លោកបង្គាប់ឲ្យស៊ឹមឈប់ឡាន ហើយលោកចុះទៅដី។លោកប្រាប់ស៊ឹមថា៖

- ស៊ឹមឯងបរឡានទៅផ្ទះចុះ ប្រាប់ប្រពន្ធខ្ញុំថាកុំចាំបាយខ្ញុំល្ងាចនេះ។ស៊ឹមបរឡានមកផ្ទះយកទៅចតដាក់ស្រួលបួល រួចក៏ឡើងទៅលើផ្ទះជម្រាបប្រពន្ធលោក។

នារីពាក់មាសប្រកបដោយបន្តោងពេជ្រទាំងគ្រាប់ មុនមិនសប្បាយបានសួរបញ្ជាក់ស៊ឹម៖

- លោកស៊ឹមឯងអញ្ជើញទៅណា?
- បាទ ខ្ញុំមិនដឹងទេ។
- ស៊ឹមឯងកុំលាក់ លោកទៅណា?
- លោកគ្រាន់តែប្រើខ្ញុំបាទមកជម្រាបថាលោកមិនមកពិសាបាយទេល្ងាចនេះ។
- អញដឹងហើយ។បើមិនទៅមីទឹកល្អក់ មុនជាទៅមីទួលតាពូង។គង់តែស្គាល់ដៃទេថ្ងៃណាមួយ។

## ៩- ទៅមុន

ស៊ឹមបើកឡានចេញផុតពីរបងមន្ទីរធ្វើការ សួរះ

- តេជគុណអញ្ជើញទៅណា?
- បត់ទៅអាថៃសាន ខ្ញុំត្រូវទៅជួបគេ។លោកបានបង្គាប់។

ស៊ឹមបរសំដៅទៅអាថៃសាន ដល់មុខរោងកុនទ្រឿងកុកឈប់។មុននឹងចុះ លោកបានមើលម៉ោងរួចបង្គាប់៖

- ស៊ឹមឯងទៅទទួលកូនខ្ញុំសិនចុះ ដល់ម៉ោង១១កន្លះ ត្រូវត្រឡប់មកទទួលខ្ញុំវិញ
- ប្របាទទាន...។

ឆ្លើយរួច ស៊ឹមបានបរឡានទៅសាលារៀនបារាំងខាងលិចវត្តភ្នំ ទទួលកូនលោកជូនទៅផ្ទះរួចជាស្រេច ក៏បានបរឡានត្រឡប់មកដល់អាថៃសានវិញជិតម៉ោង១១កន្លះ។ស៊ឹមចោលភ្នែកទៅក្នុងហាងអាថៃសាន ឃើញចៅហ្វាយគាត់អង្គុយជាមួយលោកបីនាក់ទៀតដល់ម៉ោង១១កន្លះ ស៊ឹមចោលភ្នែកទៅម្តងទៀត ឃើញមិត្តលោកម្ចាស់ថែមមួយដូសទៀត អផ្សុកពេកណាស់ ដល់ពេលប្រពន្ធចាំបាយផង ស៊ឹមបានចុះពីឡានដើរទៅបៀតចិនលក់ទឹកកក មើលរូបកុនដែលបិទនៅជញ្ជាំងទ្រឿងកុក។សារ៉ែនស្រែកឡើងស៊ឹមទៅថៃសាន ឃើញអ្នកបម្រើចាក់ឲ្យលោកមួយដូសទៀត ហើយអ្នកឡើងតុទាំងបួនជជែកគ្នាយ៉ាងរីករាយ។ឃើញដូចនេះ ស៊ឹមលាន់មាត់ម្នាក់ឯងថា “មិនមែនតែម្តងនេះទេ ម៉េចក៏ម៉េចចុះ អញទៅមុនហើយ...” ។

រួចពីរអ៊ូនេះស៊ឹមក៏ឡើងឡាន បញ្ឆេះរោទិ៍ម៉ាស៊ីនយ៉ាងខ្លាំងឲ្យលោកឮ តែលោកមិនឮ ស៊ឹមក៏ដាក់លេខបើកឡានមកផ្ទះមុន។ចតរទេះឡានក្នុងរោងស្រួលបួលរួច ស៊ឹមក៏ជិះកង់កញ្ចាស់មកផ្ទះគាត់។ដល់ម៉ោងមួយជិតកន្លះ ស៊ឹមបានស្លៀកពាក់ជិះកង់ទៅផ្ទះលោក ជូនកូនលោកទៅសាលារៀន ហើយក៏ត្រឡប់មកចាំលោកវិញ។កំពុងតែជូតឡាន ស្រាប់តែឮសម្លេងលោកមកពីលើផ្ទះស្រែកហៅថា៖

- ស៊ឹមឡើងមកលើ។

ស៊ឹមបានរត់ឡើងទៅលើផ្ទះ រួចសួរះ

- មានការអ្វីហៅខ្ញុំបាទទាន?
- ហេតុអ្វីក៏បើកឡានចោលខ្ញុំពីថ្ងៃត្រង់នេះ? លោកបាននិយាយមើលមុខស៊ឹមដោយខឹង។
- ខ្ញុំបាទចាំតេជគុណដល់ម៉ោង១២ សារ៉ែនស្រែកបានខ្ញុំបាទចេញឡានមក...។
- ស៊ឹមឯងធ្វើការស្រេចតែចិត្តស៊ឹមឯងឬ? លោកបានកាត់ញ៉ូវមាត់។
- បាទទេ តេជគុណឲ្យខ្ញុំបាទចាំត្រឹមតែម៉ោង១១កន្លះ។ខ្ញុំបាទចាំរហូតដល់ម៉ោង១២ យូរលើសកន្លះម៉ោងពីតេជគុណបង្គាប់ ខ្ញុំបាទស្មានតែតេជគុណមិនអញ្ជើញមកពិសាបាយផ្ទះ។
- ឃើញខ្ញុំរាប់អានស៊ឹមឯងមើលងាយខ្ញុំណាស់។លោកបានបន្ទោស។

- ខ្ញុំបាទមើលងាយតេជគុណឯណា? ខ្ញុំបាទខំយកចិត្តទុកដាក់ថែទាំឡានតេជគុណ ហើយខំផ្គាប់ជូនកូនតេជគុណ ជូនលោកស្រី ទៅរៀន ទៅផ្សារ...។
- កុំជជែកជាមួយអាមនុស្សតូចតាចនោះ។បើវាមិនស្ដាប់កោតខ្លាចចៅហ្វាយនាយទេ ផ្លាស់វាទៅ ដេញវាចោលទៅ។ខ្វះអីមនុស្សបរឡាន។លោកស្រីដែលនៅក្បែរនោះបានអារកាត់។

ឮលោកស្រីឡើងសម្លេងដូចនេះ លោកប្រុសក៏ឈប់និយាយ។លោកចុះមកដីឡើងឡាន។ស៊ឹមក៏បានបរឡានសំដៅទៅមន្ទីរធ្វើការ។

ចូលក្នុងរបងមន្ទីរធ្វើការ ស៊ឹមបានចតឡានទុកស្រួលបួលហើយ ក៏ចុះពីឡានដើរសំដៅទៅគល់ឈើដែលពូសនបានអង្គុយនៅទីនោះ។ពូសនបានឃើញក៏សួរះ

- មានដំណឹងអ្វីប្លែកទៀតទេស៊ឹម?
- បាទមានច្រើនណាស់ ហើយពិសេសថ្ងៃនេះគឺរឿងផ្ទាល់ខ្លួនខ្ញុំនឹងលោក។
- រឿងដូចម្ដេចទៅ?
- រឿងលោកចង់ផ្លាស់ខ្ញុំចោល។
- ព្រោះអ្វី?
- ព្រោះខ្ញុំបានបើកឡានចោលលោកពីថ្ងៃត្រង់នេះ។លោកឲ្យខ្ញុំចាំលោកនៅមុខថៃសាន សន្យាត្រឹមម៉ោង១១កន្លះ។ខ្ញុំចាំដល់សាវ៉ែនស្រែក តែលោកមិនគិតខ្ញុំចាំលោកសោះ លោកនិងមិត្តលោកចេះតែថែមមួយដូស ហើយមួយដូសទៀត...។ខ្ញុំឃ្លានបាយពេកទ្រាំមិនបាន ក៏បើកឡានទៅមុនទៅ...។
- ម្ដេចអីចឹងស៊ឹម ឯងលេងធំណាស់តើ ប៉ានបើកឡានចោលចៅហ្វាយ។ពូសនបន្ទោស។
- យើងធ្វើការមានម៉ោង មានពេលពូ។យើងមានភារៈជូនមកមន្ទីរធ្វើការ ហើយនឹងធ្វើការក្នុងរាជការជាការចប់ មិនមែនបើកប្រាក់ខែខ្វះព្រឹកល្ងាច បើកឡានជូនគេស៊ីផឹកដូចនេះទេ...។
- ឥឡូវលោកគិតដូចម្ដេច?
- លោកស្រីថា ខ្ញុំជាមនុស្សតូចតាច ហើយប្រាប់លោកឲ្យផ្លាស់ខ្ញុំចោល។
- ស៊ឹមឯងត្រូវទៅសុំទោសលោកទៅ...។
- ខ្ញុំមានទោសឯណាសុំ ខ្ញុំធ្វើតាមច្បាប់ បើលោករៀនចេះច្បាប់ហើយមិនគោរពច្បាប់ មុខតែយើងតូចតាចទាំងអស់វេទនាជានិច្ច។ថ្ងៃនេះវេនខ្ញុំ ថ្ងៃស្អែកវេនពូ ថ្ងៃក្រោយវេនអ្នកបើកឡានទាំងអស់គ្នា...។
- ឱនដាក់គ្រាប់ ដើបវាស្កកស៊ឹម។ពូសនទូន្មាន។ឯងត្រូវគិតដល់កូនប្រពន្ធផង...។
- ខ្ញុំគិតដល់កូនប្រពន្ធហើយ បានជាខ្ញុំការពារកម្រិតម៉ោងធ្វើការឲ្យត្រឹមត្រូវតាមច្បាប់ កុំឲ្យមានការរំលោភគ្រប់នាទីដូចនេះ... ដើម្បីខ្ញុំអាចថែទាំវាឲ្យបានសុខ រៀនស្រួល...។
- ពងមាន់កុំជល់នឹងថ្មស៊ឹម។ពូសនបានប្រដៅថែម។ឯងស្ដាប់ពូ។ពូបើកឡានយូរហើយ មានចៅហ្វាយបារាំងខ្មែរ។ពូមិនដែលប៉ានទទឹងម្ដងណាឡើយ លោកប្រើធ្វើម៉ាន ពូធ្វើភ្លាម។ចៅហ្វាយពូចូលចិត្តជា

និច្ច ព្រួយចិត្តកាត់សាញ ពូដាក់អាជីវហៃ អាកំពង់ត្រាំមួយកែវរួចខ្លួនស្រេច។កុំចេះពេក កុំប្រាជ្ញពេកស៊ឹម ប្រយ័ត្នចោលប្រពន្ធកូន...។

- ពូជាន់ចាស់។ខ្ញុំសម័យថ្មី ក្នុងស្រុកឯករាជ្យ ប្រជាធិបតេយ្យ ខ្ញុំត្រូវតែខំ ត្រូវតែដឹងដើម្បីការងារ សេរីភាព សិទ្ធិរបស់យើងរាល់គ្នា។
- ក្មេងៗឥឡូវចចេសណាស់។អាកូនខ្ញុំក៏រឹងណាស់ដែរ។មួយថ្ងៃៗ ពូតែវាពន្យល់ម៉ែវា បងស្រីវាថា អាមេរិចខូចណាស់ ចង់យកខ្មែរជាចំណុះវាដូចជាបារាំងអីចឹង ខ្ញុំជេរស្តីវា សួរថាដឹងពីណាមក។វាថាមកពីវាមើលកាសែតនង្គ័លរាល់ថ្ងៃអង្គារ និងសុក្រ។
- ខ្មែរឥឡូវក្រោកហើយ។កុំរាំងរា ទប់មិនជាប់ទេ។បារាំងធ្លាក់ទឹកហើយ ពូមិនឃើញទេឬ?
- ស៊ឹមឯងត្រូវគិតមែនទែន។សូមទោសលោកទៅ។កុំប៉ានបម្រះនឹងលោក...។
- ខ្ញុំសូមតែយុត្តិធម៌ សូមតែធ្វើការត្រឹមម៉ោងប៉ុណ្ណោះជាការចប់។
- ឈប់និយាយស៊ឹម។យើងស្តាប់គ្នាមិនបានទេ។

ពូសនបានបញ្ចប់ រួចគាត់ក្រោកដើរសំដៅទៅឡានគាត់។

# ១០- អស់ការធ្វើ

បើកបិទៗ ច័ន្ទកន្លង អង្គារមកដល់...។អាទិត្យចាស់ឈាន អាទិត្យថ្មីរះ។មួយខែ ពីរខែ... ប្រាំមួយខែកន្លងផុតទៅ ហ្វូងគូលីបានគូរវាសលើដីវាលនូវគំនូរផ្សេងៗ។ដីក្រហេង ក្រហូងត្រូវបានចាក់រាបស្មើប្រកបដោយផ្លូវក្រឡាតូចៗខ្វាត់ខ្វែងព័ទ្ធជុំវិញសួនច្បារ ដែលមានផ្កាក្រហម ស រីកស្រស់ញញឹម។ផ្ទះពីរខ្នង ពីរជាន់ធំសម្បើមលាបពណ៌ថ្មីថៃស បានផុសត្រដែតទន្ទឹមគ្នា។ផ្ទះទាបតូចពីរខ្នងទៀត បានអមជាបរិវារផង។

អ្នកដំណើរទៅមកលើផ្លូវជាតិលេខមួយ កាត់ចំមុខផ្ទះនេះ មានអ្នកជិះឡាន អ្នកដើរជើង អ្នកជិះកង់ អ្នកជិះស៊ីក្លូ សុទ្ធតែបានលាន់មាត់គ្រប់គ្នាថា "ធ្វើរហ័សមែន ភូមិនេះបានចំជាសម្បើម ម្ចាស់គេរកស៊ីអ្វីហ្ន៎ គេបានលុយពីណា ច្រើនម្លេះ។

អ្នកដំណើរខ្លះបានជជែកឆ្លើយព្រាវៗ ខ្លះថាផ្ទះអាមេរិច ខ្លះថាផ្ទះបារាំង ខ្លះថាផ្ទះអុងប៉ាង... ខ្លះថាផ្ទះរដ្ឋមន្ត្រី ខ្លះថាផ្ទះរាជការ ខ្លះថាផ្ទះសំណាក់ ខ្លះថាផ្ទះចៅហ្វាយខេត្ត។

ផ្ទះដ៏ធំសម្បើមនេះ ក្រៅពីនាំសេចក្តីងឿងឆ្ងល់ដល់អ្នកដំណើរ បាននាំក្តីព្រួយសប្បាយទៅលើមនុស្សបីពួកច្រើនជាងគេ។

ចៅកែទទួលម៉ៅការធ្វើការបានញញឹមជាប់។គាត់ធ្វើបញ្ជីគិតលុយកាក់ទូទាត់ត្រូវឆ្វេង ស្តាំ ឃើញនៅចំណេញជិតមួយលានរៀលទៀត។

ម្ចាស់ផ្ទះបានជិះឡានម៉ាកអាអូប៉ែលចេញ ចូលភូមិ មុខរីកជាប់ មើលគេឯងបែបត្រង់ចង់បង្ហាញប្រាប់អ្នកជិតខាងថា ខ្លួននេះហើយជាអ្នកមកនៅក្នុងមហាផ្ទះទំនើបសម្បើមក្នុងអាទិត្យក្រោយ។

ឯចំណែកគូលី គេបានខ្វល់នឹងបញ្ហាផ្ទាល់ខ្លួនរបស់គេដែរ។ផ្ទះសង់ជិតរួច ការក៏កាន់តែមានស្ងួចស្តើង ចំនួនគូលីក៏ចេះតែថយចុះជាលំដាប់។រាល់ថ្ងៃកន្លងទៅ គូលីច្រើននាក់ត្រូវបញ្ឈប់លែងឲ្យធ្វើការ។វាលសង់ផ្ទះដែលមានគូលីមីរដេរដាស ប្រញាប់ដៃ ញាប់ជើងរស់រវើក កាលប្រាំមួយខែមុនបានប្រែស្ថានភាពស្ងាត់ ទុកគូលីមិនដល់១០នាក់ផង។មីងប្រេម នាងប្រុញ ហ៊ី ម៉េង និងគូលីបីនាក់ទៀតបានមានការធ្វើនៅឡើយ។គូលីដែលនៅស្ងួចស្តើង គ្មានជជែកអ្វីក្រៅពីក្តីព្រួយអត់ការធ្វើទេ។នៅជិតពេលបែកគ្នាទៅរកផ្លូវរស់ផ្សេងៗទៀត ម៉េងបានហៅស៊ឹមមកបាយថ្ងៃត្រង់ជាមួយ។នៅពេលជួបគ្នាក្រោយនេះ គេគ្មាននិយាយអ្វីក្រៅពីបញ្ហាផ្ទាល់ក្រុមឡើយ ម៉េងបានផ្តើមនិយាយ៖

- អាទិត្យក្រោយអស់ការធ្វើនៅទីនេះ។ហាងប្រគល់ផ្ទះទៅម្ចាស់។យើងអស់មានច្បាប់ចេញចូលទៀតហើយ។
- ខ្ញុំទាល់ច្រកហើយ មិនដឹងជាទៅធ្វើឯណាទៀតទេ។មីងប្រេមត្អូញ។
- ឯចំណែកខ្ញុំ ខ្ញុំត្រឡប់ទៅភូមិបាត់ដឹងវិញ ទៅមើលកូន ប្រពន្ធចូលឆ្នាំថ្មីនេះ។ដល់ខែពិសាខ ខ្ញុំធ្វើស្រែវិញ។ហ៊ីបានប្រាប់។
- គ្មានហាងឯងគេរកគូលីទេឬ? ពូជួយយើងផង។(នាងប្រុញបានសួរ)

- មានដែរ។ស៊ីមបានឆ្លើយ។កាលពីថ្ងៃព្រហស្បតិ៍មុន អាប្អូនខ្ញុំវាស្ម័គ្រចិត្តទៅសូមធ្វើផែកំពង់សោម។គេបានឆ្លើយប្រាប់វាថា គេមិនយកទាំងអស់គ្នាទេ ហើយគេថាចាំខែក្រោយបានគេឲ្យដំណឹង ព្រោះឥឡូវមិនទាន់មានម៉ាស៊ីនមកដល់..។អាប្អូនខ្ញុំវាថា វាមិនសង្ឃឹមបានទៅកំពង់សោមទេ ព្រោះមនុស្សច្រើនណាស់ គេបានទៅត្រសុលក្បាលទៅរករស់នៅកំពង់សោម ឯមេបាងបែបមិនចង់មើលមុខយើងផង។
- មើលបងស៊ីមឯងមានដឹងទេ តើស្រុកគេមនុស្សអត់ការធ្វើ ដោះស្រាយដូចម្ដេច?

ស៊ីមមើលនាឡិកាដៃគាត់ រួចនិយាយះ

- យើងមានពេលខ្លីណាស់។ខ្ញុំត្រូវចេញពីនេះម៉ោងមួយ ដើម្បីទៅទទួលលោកខ្ញុំ...។ល្ហើយ ខ្ញុំសូមនិយាយកាត់ៗបន្តិចចុះ។នៅប្រទេសគេ គូលីកម្មករសុទ្ធតែមានសមាគម សហជីព។សហជីពជាអង្គការរបស់អ្នកលក់កម្លាំងដូចយើង។សហជីពមានភារៈសំខាន់ប្រមូលផ្ដុំក្រុមគូលីកម្មករដើម្បីការពារក្រុមខ្លួនដូចជាទាមទារឲ្យបានប្រាក់ឈ្នួលគ្រប់គ្រាន់ និងតវ៉ាឲ្យមានការធ្វើគ្រប់គ្នា ហើយកុំឲ្យហាងរំលោភឲ្យធ្វើការហួសពេលកម្រិត។បើកម្មករណាគ្មានការធ្វើ កម្មករនោះត្រូវទៅស្នើសហជីព ឬមានសមាគមឲ្យចិញ្ចឹមខ្លួនបណ្ដោះអាសន្ន ហើយនឹងទៅតវ៉ារាជការឲ្យរកការឲ្យធ្វើទាល់តែបាន។ឯចំណែកនៅស្រុកយើង មិនទាន់មានសហជីពនេះហើយ បានជាយើងនៅបែកខ្ញែកគ្នា ហើយស្រេចតែគេប្រើញញក់ញញីបានតាមចិត្ត។ដោយខ្វះអង្គការនេះហើយ បានជាយើងអណ្ដែតអណ្ដូង មិនដឹងទៅទីណាប្រាកដដល់គេដេញយើងអាទិត្យក្រោយ ...។
- បើដូចនេះ សហជីពសំខាន់ណាស់។សម្លេងមួយបានបញ្ជាក់។
- វាជាថ្លើមបេះដូងរបស់អ្នកធ្វើការរាល់រូប ដើម្បីឲ្យមានសិទ្ធិតវ៉ាកុំឲ្យមានការអត់ឃ្លាន កុំឲ្យគេជិះជាន់បានតាមចិត្ត។
- គ្រប់សហជីពមានគោលបំណងដូចគ្នាឬ? ម៉េងបានសួរបញ្ជាក់។
- នៅស្រុកខ្លះដោយទប់មិនបាននឹងកម្លាំងប្រជាជន អ្នកកាន់អំណាចបានចាត់តាំងសហជីព ឬសមាគមរបស់គេ ដើម្បីគេស្រួលក្ដាប់ប្រជាជនឲ្យនៅក្នុងស័ងគេទៀត នៅប្រទេសបារាំងពួកនាយទុនបារាំងបានចាត់តាំងសហជីពមួយ ពីរ ដើម្បីឲ្យសហជីពនេះ ប្រឆាំងនឹងសហជីព ឬសមាគមប្រជាជនពិតប្រាកដ។ហេតុនេះហើយបានជាយើងឮជាញឹកថា មានសហជីពខ្លះមិនព្រមជួយតវ៉ាឲ្យប្រជាជនស៊ីឆ្អែតទេ ផ្ទុយទៅវិញ គេដាក់កំហុសទៅលើគូលី...។
- បើដូចនេះយើងត្រូវប្រយ័ត្ន មិនស្រួលទេ។ម៉េងលាន់មាត់។
- ដល់ម៉ោងហើយ។ស៊ីមបាននិយាយត។ខ្ញុំល្មមទៅ...។សូមមីង បងហ៊ី និងម៉េងឲ្យដំណឹងខ្ញុំផង បើគង់តែទៅឯណាក៏ដោយ។ខ្ញុំលាហើយ។

ថារួច ស៊ីមកន្ត្រាក់កង់កញ្ជាស់គាត់ជិះខ្វឹតសំដៅទៅផ្ទះលោក ...។

# ១១- ភ្ញាក់រលឹក

ថ្ងៃរសៀលម៉ោងជាងបី ពូសនបើកឡានទៅដល់មន្ទីរធ្វើការ... ឃើញស៊ឹមកំពុងតែមើលសៀវភៅអង្គុយលើអាស៊ីបកញ្ចាស់គាត់។ពូសនចតឡានស្រួលបួលហើយ រួចក៏ដើរសំដៅទៅស៊ឹម សួរថា៖

- ស៊ឹមជក់រឿងណាស់ថ្ងៃនេះ មិនឮសូរឡានខ្ញុំទេឬ? សុខសប្បាយជាទេ។

ស៊ឹមឮសម្លេងក៏ងាកមើល បិទសៀវភៅហើយឆ្លើយតប៖

- ចុះពូសុខសប្បាយជាទេ? ទៅណាបាត់ជាងមួយអាទិត្យ? ខ្ញុំស្មានតែមិនមែនពូបើកឡាននេះ បានជាខ្ញុំមិនសូវគិត។
- លោកពឹងពូឲ្យជូនបងប្អូនលោកទៅលេងកែប...។
- ម៉េចសប្បាយទេ ទៅលេងកែប។ស៊ឹមបានសួរ។បានក្តាម ត្រីសមុទ្រយកមកផ្ញើខ្ញុំខ្លះទេ...។
- មិនបានទេស៊ឹមអើយ ឯងមិនសូវមានលុយនោះ។លើកនេះយ៉ាប់ណាស់ ឡានខូច បូមសាំងមិនសូវស្រួលសោះ។ម្យ៉ាងទៀតប្រើរក់រីតែម្តងហើយ បន្តិចកែប បន្តិចទឹកឈូ។ខ្ញុំនៅជាប់នឹងឡាន គ្មានហ៊ានឲ្យអ្នកណាកាន់ជួសទេ ម្លោះហើយស៊ឹមឯង គ្រាន់តែភ្លេចកន្សែងមួយទៅជូតខ្លួន ក៏ប្រើឯងទៅយកដែរ។
- ក្រែងបានរង្វាន់ខ្លះដែរ...។ស៊ឹមបានបញ្ជាក់។
- ឲ្យដែរតែតិចណាស់។គ្រាន់តែផឹកកម្តៅគ្រឿងក្នុង មិនចង់គ្រប់ផង។ពូត្រូវចាយលុយផ្ទាល់ខ្លួនអស់៥០រៀលទៀត។ម្យ៉ាងទៀត អាទិត្យមុននេះ នៅផ្ទះមានធុរៈ។មីងឯងគេមិនស្រួល ចេះតែចុកពោះ។ពូទៅកែបលើកនេះ ទាំងទើសទាល់ទេ កុំឲ្យតែលោក កុំអីមិនទៅទេ...។ចុះស៊ឹមឯងវិញ លោកស៊ឹមឯងមានថាអ្វីទៀតទេ?
- លោកគ្មានថាអ្វីទេ។គ្រាន់តែលោកមិនស្និទ្ធស្នាលដូចពេលមុនទៀត។
- ស៊ឹមឯងសូមទោសលោកទៅ។
- ខ្ញុំជម្រាបច្រើនលើកហើយថា ខ្ញុំមិនសូមទេ ព្រោះខ្ញុំគ្មានខុស។
- ស៊ឹមឯងនៅតែរឹងដដែល។
- ខ្ញុំការពារសិទ្ធិសេរីភាពរបស់យើងគ្រប់គ្នា។
- លោកមិនផ្លាស់ស៊ឹមឯងទេឬ មើលទៅ?
- ត្រង់ផ្លាស់ខ្ញុំមិនដឹងសោះ ហើយខ្ញុំក៏មិនដែលនិយាយពីរឿងនេះផង។តែតាមខ្ញុំសង្កេតឃើញតាំងពីក្រោយថ្ងៃដែលខ្ញុំបើកឡានទៅមុននោះ លោកមិនបានរំលោភលើខ្ញុំទៀតទេ។ខ្ញុំឈប់ជូតឡានផ្ទាល់ខ្លួនលោកទៀតហើយ។ម្តងមួយកាលទេដែលខ្ញុំជូនកូនលោក ឬទៅទទួលកូនលោកពីសាលារៀន ហើយថ្ងៃសម្រាកអាទិត្យ ខ្ញុំបានទៅផ្ទះជាមួយកូនប្រពន្ធខ្ញុំស្រួលជាងលើកមុន។ឥឡូវខ្ញុំមានឱកាសថែទាំគ្រួសារខ្ញុំច្រើន ហើយមិនសូវហត់នឿយរក់រីដូចមុនទៀតទេ លោកស្រីក៏ប្រែនិយាយមករកខ្ញុំពីងខ្ញុំដោយសម្តីស្រួល លែងពាក្យធំៗដូចមុនទៀតហើយ។

- ពូខំតែជួយព្រួយ ជួយភ័យស្ពានតែត្រឡប់ពីកែបមកវិញនេះ ខានឃើញមុខឯងហើយ។ឯងត្រឡប់ជាគ្រាន់បើទៅវិញ។មនុស្សឥឡូវប្រែច្រើនណាស់។ជាន់ដើម របៀបស៊ឹមឯងនេះ មិនគ្រាន់តែផ្លាស់ ឬដេញចោលទេ ប្រហែលជាត្រូវឃុំខ្លះផងមើលទៅ។ពូសរសើរលោកស៊ឹមឯងណាស់ ដែលមានចិត្តល្អដូចនេះ មិនងាយរកទេ ចៅហ្វាយរបៀបនេះ...។
- ចុះពូឯង ចង់បានចៅហ្វាយនាយរបៀបនេះទេ?
- ម៉េចមិនចង់?
- បើដូចនេះ ត្រូវខំផ្លាស់របៀបចាស់ចោល គឺត្រូវខំរៀនអានសៀវភៅ អានកាសែតដូចខ្ញុំអីចឹង ហើយតែចង់ដល់យើងចេះដឹងដូចគ្នាទៅ យើងហ៊ានរកខុសត្រូវ ហើយមនុស្សធ្លាប់រំលោភជិះជាន់យើង ក៏ប្រែរជាចិត្តល្អវិញ...។
- មែន ស៊ឹមឯងនិយាយចំជាត្រូវ។តែមានអ្នកបរឡានតិចណាស់ ដែលមានគំនិត ដែលមើលឃើញដូចស៊ឹមឯង។ស៊ឹមឯងមានដឹងទេ ពួកអាសៀង ពួកអាយ៉ែម ពួកពីរនាក់នោះវាចង់ញោសជាងពូទៅទៀត។វាគិតតែលេងបៀ គិតតែផឹក...។បើវាជួបពូ វាគិតតែបបួលពូចូលតៀមចិនដាក់មួយកែវសិន។ហើយអាហោងវិញ ពិបាករកលេខដាក់ណាស់។ក្រោមពូកឡានវា មានមួយដបជានិច្ច អានោះគ្មានគិតអ្វីក្រៅពីឱបដបស្រាទេ ពេលចាំលោក...។
- គ្នាមិនទាន់យល់។ហេតុដូចនេះ យើងត្រូវតែខំកែប្រែខ្លួនយើងសិន។ក្រោយដែលយើងភ្ញាក់រលឹក កែប្រែដុសខាត់គំនិតយើងបានហើយ យើងត្រូវជួយអ្នកដទៃទៀត។ជាដំបូងនេះ ពូត្រូវខំរៀនមើលសៀវភៅ បើខ្វះខ្ញុំឲ្យខ្ចីខ្លះ។កុំទុកពេលចោលទទេ ជាងទំនេរ រៀនសូត្រទៅ។
- ចុះស៊ឹមឯងមើលសៀវភៅអីថ្ងៃនេះ ក៏ជក់មិនពុទ្ធឡានពូ...។
- ខ្ញុំមើលទំនៀមទម្លាប់ និងច្បាប់ខ្មែរ។ពូត្រូវការមើល ខ្ញុំឲ្យខ្ចី ព្រោះខ្ញុំមានយកសៀវភៅប្រវត្តិអាចារ្យហែមចៀវ មកជាមួយដែរថ្ងៃនេះ។

ថាហើយ ស៊ឹមបានហុចសៀវភៅឲ្យពូសន។ពូសនយកទៅមើល។ស៊ឹមដើរឆ្ងាយពីពូសនទៅអង្គុយលើគល់ឈើ។ពូសនមើលជក់ស្លុង ប្រហែលបានមួយសន្លឹកលោកលាន់មាត់ថា៖ “បណ្ដាំអាចារ្យហែមចៀវ ចំជាត្រូវ” រួចគាត់និយាយទៅកាន់ស៊ឹម៖ "ថ្ងៃក្រោយឲ្យពូខ្ចីសៀវភៅមើលទៀត...៕

ចប់ដោយបរិបូរណ៍